# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

sm1.sda.10

**រដ្ឋបាលរាជធានីភ្នំពេញ**

លេខ: ៤១៣/១៧ សសរ.រ

# សេចក្តីសម្រេច
## ស្តីពី
## ការកែសម្រួលសមាសភាពគណៈកម្មការគ្រប់គ្រង សិក្សាផលប៉ះពាល់ និងអភិវឌ្ឍន៍បឹងតាមោក (កប់ស្រូវ)

## អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើប្រាស់ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦១៧/៥០៣ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៧ ស្តីពីការត្រាស់បង្គាប់តែងតាំងអភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ
- បានឃើញអនុក្រឹត្យលេខ ២១៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានីភ្នំពេញ និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ
- យោងលិខិតលេខ ១២៨៦ សជណ.ផក ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៤ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- យោងភារកិច្ចចាំបាច់ចំពោះមុខ

## សម្រេច

**ប្រការ១.-**

ត្រូវបានកែសម្រួលសមាសភាពគណៈកម្មការគ្រប់គ្រង សិក្សាផលប៉ះពាល់ និងអភិវឌ្ឍន៍បឹងតាមោក (កប់ស្រូវ) ស្ថិតនៅសង្កាត់គោករកា សង្កាត់ពន្សាំង សង្កាត់ពញាពន់ សង្កាត់សំរោង និងសង្កាត់ព្រែកព្នៅ ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ ដែលមានសមាសភាពដូចខាងក្រោម៖



៦៩មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥)២៣-៧២២ ៧៣៩ / ទូរសារ : (៨៥៥)២៣-៧២៥ ៦២៦ / ២៣-៧២២ ០៥៤
www.phnompenh.gov.kh; Email : info@phnompenh.gov.kh

| | | | | |
|---|---|---|---|---|
| ១-ឯកឧត្តម | **ឃួន** | **ស្រេង** | អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ | ប្រធាន |
| ២-ឯកឧត្តម | អៀង | អូននី | អភិបាលរង នៃគណៈអភិបាលរាជធានីភ្នំពេញ | អនុប្រធាន |
| ៣-ឯកឧត្តម | មាន | ចាន់យ៉ាដា | អភិបាលរង នៃគណៈអភិបាលរាជធានីភ្នំពេញ | អនុប្រធាន |
| ៤-ឯកឧត្តម | កើត | ឆែ | អភិបាលរង នៃគណៈអភិបាលរាជធានីភ្នំពេញ | អនុប្រធាន |
| ៥-លោក | ហួត | ហៃ | នាយករដ្ឋបាលសាលារាជធានីភ្នំពេញ | សមាជិក |
| ៦-លោក | សុខ | សម្បត្តិ | អភិបាល នៃគណៈអភិបាលខណ្ឌព្រែកព្នៅ | សមាជិក |
| ៧-លោក | គាត | រង្សី | ប្រធានមន្ទីរបរិស្ថានរាជធានីភ្នំពេញ | សមាជិក |
| ៨-លោក | ម៉ៅ | ប៊ុនធឿន | ប្រធានមន្ទីរធនធានទឹក និងឧតុនិយមរាជធានីភ្នំពេញ | សមាជិក |
| ៩-លោក | សារិន | វណ្ណា | ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានីភ្នំពេញ | សមាជិក |
| ១០-លោក | សាំ | ពិសិដ្ឋ | ប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានីភ្នំពេញ | សមាជិក |
| ១១-លោក | ងី | ប៊ុនលី | ប្រធានមន្ទីររ៉ែ និងថាមពលរាជធានីភ្នំពេញ | សមាជិក |
| ១២-លោក | រ៉ា | សុធា | ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានីភ្នំពេញ | សមាជិក |
| ១៣-លោក | លឹម | វិចិត្រ | នាយករងរដ្ឋបាលសាលារាជធានីភ្នំពេញ | សមាជិក |
| ១៤-លោក | លឹម | ឡេង | នាយករងរដ្ឋបាលសាលារាជធានីភ្នំពេញ | សមាជិក |
| ១៥-លោក | ស៊ិន | បូណ៌មី | នាយកទីចាត់ការរៀបចំក្រុង | សមាជិក |
| ១៦-លោក | អ៊ុក | សុផល | នាយកទីចាត់ការហិរញ្ញវត្ថុ | សមាជិក |
| ១៧-លោក | ស៊ូ | ស៊ីវុត្ថា | ប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលខណ្ឌព្រែកព្នៅ | សមាជិក |
| ១៨-លោក | សួរ | ផារ៉ា | ប្រធានការិយាល័យគ្រប់គ្រងការអភិវឌ្ឍ និងសំណង់ | សមាជិក |
| ១៩-លោក | ផល | សុភក្ស | អនុប្រធានការិយាល័យនគរូបនីយកម្ម | សមាជិក |
| ២០-លោក | ថៃ | ស្រ៊ុន | អនុប្រធានការិ.គ្រប់គ្រងការអភិវឌ្ឍ និងសំណង់ | សមាជិក |
| ២១-លោក | នាង | មុនីរ័ត្ន | មន្ត្រីការិយាល័យគ្រប់គ្រងការអភិវឌ្ឍ និងសំណង់ | សមាជិក |
| ២២-លោក | ឡេង | ធីតា | មន្ត្រីការិយាល័យគ្រប់គ្រងការអភិវឌ្ឍ និងសំណង់ | សមាជិក |

**ប្រការ២.**_

គណៈកម្មការនេះ មានភារកិច្ចដូចខាងក្រោម ៖

១-ចូលរួមសហការជាមួយនឹងអ្នកបច្ចេកទេសរបស់ក្រសួងធនធានទឹក និងឧតុនិយម និងក្រសួងបរិស្ថាន៖

-ចុះសិក្សាស្រាវជ្រាវនូវផលប៉ះពាល់គុណភាពទឹក និងល្បាយទឹកនៅក្នុងបឹងតាមោក (កប់ស្រូវ) សម្រាប់ការលើកទំនប់ការពារបរិស្ថានទាំងពេលបច្ចុប្បន្ន និងទៅអនាគត។

-ចុះកំណត់ព្រំប្រទល់ផ្ទៃបឹងតាមោក (កប់ស្រូវ) ឲ្យបានជាក់លាក់ ដោយមាននិយាមការច្បាស់លាស់។

២-រៀបចំប្លង់ទីតាំងសម្រាប់ដឹកស្តារស្ថាបនាអាងចម្រោះ សិក្សាប្លង់សួនជុំវិញព្រំប្រទល់បឹងនិងសិក្សាទីតាំងបណ្តុះកូនឈើ។

៣-ចាត់ចែងប្រើប្រាស់អាចម៍ដីបានពីការដឹកស្តារបឹងដើម្បីយកទៅលើកទំនប់បន្ត។



៦៩មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥)២៣-៧២២ ៧៣៩ / ទូរសារ : (៨៥៥)២៣-៧២៥ ៦២៦ / ២៣-៧២២ ០៥៤
www.phnompenh.gov.kh; Email : info@phnompenh.gov.kh